## រណសិរ្សរំដោះជាតិខ្មែរ

### ជាតិ សាសនា ប្រជាជាតិខ្មែរ

ការិយាល័យលេខ 22/14 រ.ស.រ.ជ.ខ

# សេចក្តីថ្លែងការណ៍

**រណសិរ្សរំដោះជាតិខ្មែរ**ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះអាជ្ញាធរកុម្មុយនីស្តផ្តាច់ការ គណបក្សប្រជាជនកម្ពុជា ហ៊ុន សែន ដែលបានរារាំងក្រុមព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរ មិនឱ្យធ្វើកូដកម្មនៅមុខស្ថានទូតចិននា ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤។

រណសិរ្សរំដោះជាតិខ្មែរមើលឃើញថាកុម្មុយនីស្តចិនបានជាប់ពាក់ព័ន្ធ និងអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្មែរ នៅឆ្នាំ១៩៧៥-១៩៧៩ ហើយបានគាំទ្រយួន និងខ្មែរក្រហម ដើម្បីមកផ្តួលរបបខ្មែរសាធារណៈរដ្ឋលន់ នល់ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ធ្វើឱ្យប្រជាជាតិខ្មែរស្លាប់រាប់លាននាក់ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។

កុម្មុយនីស្តចិនបានគាំទ្រឱ្យយួន  ហូ ជីមិញ បង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិននៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៣០ ទីក្រុងហុងកុងប្រទេសចិន និងបានឧបត្ថម្ភទាំងសេដ្ឋកិច្ច សព្វាវុធគ្រាប់រំសេវ ដើម្បីឱ្យយួនបង្កើតសាខាបក្សកុម្មុយនីស្តនៅលើទឹកដីខ្មែរ ។ ចិនបានរំលោភកិច្ចព្រមព្រាងទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ដូចជាគាំទ្រហ៊ុន សែន  ប្រព្រឹត្តឧក្រិដ្ឋកម្មដោយបានយកខ្មែរទៅស្លាប់នៅតំបន់ក៥ បោកគ្រាប់បែកនៅមុខរដ្ឋសភា ឆ្នាំ១៩៩៧ ធ្វើរដ្ឋប្រហារសម្លាប់អ្នកប្រជាធិបតេយ្យនៅឆ្នាំ១៩៩៧ បាញ់សម្លាប់ព្រះតេជគុណ **សម ប៊ុនធឿន** លោក **ជា វិជ្ជា** លោកឈុត **វុទ្ធី** ជាដើម និងថ្មីៗនេះបានបាញ់សម្លាប់បាតុករនៅផ្លូវវេងស្រេងនាថ្ងៃទី៣-៤ ខែមករា ឆ្នាំ២០១៣ ថែមទាំងរឹបអូសដីធ្លី ផ្ទះសម្បែងប្រជាពលរដ្ឋខ្មែរឱ្យក្រុមហ៊ុន យួន ចិន គ្រប់ខេត្តក្រុង ថែមទាំងអនុញ្ញាតិអោយក្រុមហ៊ុនចិនជីករ៉ែកកាយភ្នំ រឹបអូសយកមាសពេជ្រមានតំលៃក្រោមដីលើដី កាប់បំផ្លាញព្រៃឈើ ធ្វើអោយប្រទេសជាតិខ្មែររលំរលាយអស់។ ទង្វើទាំងអស់នេះគឺជាការឈ្លានពាន និងរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ថែមទាំងខុសច្បាប់ជាតិ និងអន្តរជាតិ។

**រណសិរ្សរំដោះជាតិខ្មែរ**នឹងទាមទារលើឆាកអន្តរជាតិ និងអង្គការសហប្រជាជាតិ ដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះខ្មែរគ្រប់រូប ឱ្យមានសន្តិភាព សិទ្ធិសេរីភាព និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដនាពេលខាងមុខដ៏ខ្លីនេះ។

ធ្វើនៅប្រទេសថៃ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤

គណៈកម្មការ រ.ស.រ.ជ.ខ.

<u>ចម្លងជូន</u>

- គ្រប់សាខា និងសមាជិករបស់រណសិរ្សរំដោះជាតិខ្មែរ
- ផ្សព្វផ្សាយជាសាធារណៈ
- ឯកសារកាលប្បវត្តិ

ទីស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ រ.ស.រ.ជ.ខ, ប្រអប់សំបុត្រលេខ ៣៣៩០,ហ៊ុនិស្ទីល ប្រទេសដាណឺម៉ាក
Temporary Headquarter of K.N.L.F : P.O. Box 3390, Hundested, Denmark
Tel:(+45)6113 4479; E-mail: kn_lf@yahoo.dk; Website: www.knlf.org, www,knlf.net